


# ឆ្នាំសិក្សាទី៣

## McMillan House គឺឆ្នាំសិក្សាទី៣របស់មហាវិទ្យាល័យ ហើយជ្រើសរើសសំរាប់ក្មេងៗពី ELC ទៅឆ្នាំទី៤ ដោយមិត្តភាព និងការយកចិត្តទុកដាក់។

នៅក្នុងកន្លែងសិក្សាទំនើប, ឆ្នាំសិក្សាទី៣របស់យើងបណ្តុះបណ្តាលភាពវៃឆ្លាត, ការច្នៃប្រឌិតនិងទស្សនៈអន្តរជាតិ។ ផលិតអ្នកដឹកនាំដែលមានភាពទំនួលខុសត្រូវ និងចិត្តមេត្តា ដែលគិតពីសុខុមាលភាពអ្នកដទៃជាមុន និងដែលមានឆន្ទៈក្នុងការប្រឈមនឹងភាពលំបាកក្នុងសតវត្សរ៍របស់យើង ចាត់ទុកវាជាឱកាសដើម្បីធ្វើឱ្យមានភាពខុសប្លែក។យើងជឿជាក់ថាក្មេងគ្រប់រូបគួរតែជាអ្នកចូលរួមដែលមានសមត្ថភាព, អង់អាច និងសកម្មក្នុងដំណើរសិក្សារបស់ពួកគេផ្ទាល់។

ការប្រមូលផ្តុំគ្នា, ល្បែងកំសាន្តក្នុងសួនកុមារ, ការបង្រៀនពីសិស្សច្បងទៅសិស្សប្អូន និងសកម្មភាពពិសេសរបស់មហាវិទ្យាល័យទាំងមូល មានន័យថា ក្មេងៗនិងបុគ្គលិកនៅ McMillan House ស្គាល់គ្នាទៅវិញទៅមក ហើយបរិយាកាសរៀនសូត្ររីករាយមួយត្រូវបានបង្កើតឡើង។

បុគ្គលិកជំនាញផ្សេងៗគ្នាបានចូលរួមក្នុង McMillan House, រួមបញ្ចូលទាំងគ្រូបណ្ណាល័យ, គ្រូតន្ត្រី, គ្រូសិល្បៈ និងគ្រូអប់រំរាងកាយ, គ្រូវិន័យ, គ្រូជំរុញការសិក្សា, និងគ្រូជំនាញភាសា( ចិន )។

កម្មវិធីរបស់យើងនៅ McMillan House ធ្វើតាមកម្មវិធីឆ្នាំដំបូងBaccalaureateអន្តរជាតិ ( IB PYP )។ ត្រូវបានរចនាឡើងយ៉ាងជំនាញសំរាប់ក្មេងៗអាយុពី៣ទៅ១២ឆ្នាំ, PYP គឺជាគម្រោងកម្មវិធីសិក្សាមួយ ដែលបង្រៀនសិស្សអោយត្រៀមខ្លួនស្រេចសំរាប់ភាពលំបាកខាងបញ្ញា និងអារម្មណ៍នៃការអប់រំបន្តវែងឆ្ងាយ និងការងារលំដាប់សកល។កម្មវិធីនេះបញ្ចូលបញ្ហាក្នុងតំបន់ និងសកលលោកទៅក្នុងកម្មវិធីសិក្សា, ដោយស្នើសុំឱ្យសិស្សពិនិត្យមើលប្រធានបទពាក់ព័ន្ធនិងមែកធាងនៃចំណេះដឹងចំនួន ៦ ហើយពិចារណាពីទំនាក់ទំនងរវាងពួកវា។ផ្នែកនៃការសាកសួរទាំងនេះជួយជំរុញដល់ការសិក្សា, ការរីកចម្រើនផ្នែកសង្គម និងអារម្មណ៍ហើយផ្តោតលើគំនិតអន្តរជាតិ និងការអភិវឌ្ឍគុណតម្លៃផ្ទាល់ខ្លួនដ៏រឹងមាំ។ សំខាន់, PYPផ្តល់តម្លៃដល់ ឯករាជ្យភាព, ភាពផ្តួចផ្តើមគំនិត និងការលើកទឹកចិត្តខ្លួនឯង, លើកទឹកចិត្តសិស្សគ្រប់រូបឱ្យទទួលខុសត្រូវចំពោះការរៀនសូត្ររបស់ពួកគេ។